ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១០២២/២៦.១០.២០១២

សាលដីកា

លេខ: ៩៥ ក្រIIIស/២៥.១១.២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១០២២ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ រវាង ៖

១. ជនជាប់ចោទឈ្មោះ[redacted]ចិត្រ ហៅ ផែប ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរៈនៅផ្ទះ កើតនៅភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃ[redacted] លេខ២ ក្រុម១ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស) ម្ដាយឈ្មោះ[redacted](រ) នៅលីវ ទោសពីមុនមាន (ធ្លាប់ជាប់ពន្ធនាគារព្រៃសរយៈពេល០១ឆ្នាំ០៦ខែ) ឃាត់ខ្លួនថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ តែអារចម្រឹងដៃករត់ចេញពីគុក ហើយចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៨៧៦ តព្រ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

មានមេធាវីការពារលោ[redacted]បុល។

ជាប់ចោទពីបទៈ ប្លន់ (លួចគាស់បន្ទប់យកម៉ូតូ, លុយ, សម្ភារៈ) ប្រព្រឹត្តនៅ ផ្ទះសំណាក់ម្ដុំផ្សារកំបូល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។



Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្រ្ត ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរៈគ្រូបង្រៀន បច្ចុប្បន្នរស់នៅ ភូមិព្រៃបឹង ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល។

**៦ដំណើររឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ [redacted] សុភ័ក្រ្ត បានទុកម៉ូតូនៅក្នុងបន្ទប់លេខ ០៩ ក្នុងផ្ទះសំណាក់ខូយឡាក់ ដែលជាបន្ទប់ដេករបស់ខ្លួន ដោយពុំបានចាក់សោឡើយ ហើយបានយកពូកមកដាក់លើឥដ្ឋមុខមុខទ្វារ ដេកតែម្តង។ លុះពេលដឹងខ្លួនឡើងនៅវេលាម៉ោង ៣ និង៥០នាទី ជិតភ្លឺ ឃើញទ្វារកញ្ចក់ចំហរនិងបាត់ម៉ូតូព្រមទាំងសម្ភារៈមួយចំនួន។ ក្រោយមក នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ សមត្ថកិច្ចនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ នៃស្នងការនគរបាលរាជធានីភ្នំពេញ បានឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់ ជាបន្តបន្ទាប់មានឈ្មោ[redacted]ត្រ, ឈ្មោ[redacted]ចំរើន, ឈ្មោ[redacted]ពិសិដ្ឋ និងលេ[redacted] សោភ័ណ្ឌ ដោយបានដកហូតម៉ូតូម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ សេរី២០០៦ របស់ជនរងគ្រោះមកវិញ និងអាវុធខ្លីម៉ាក កា៥៤ គ្មានលេខចំនួន០១ដើម។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤០ ក្រ១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោស

ក. ឈ្មោ[redacted]ចំរើន ហៅ ម៉ាច ភេទប្រុស អាយុ២៨ឆ្នាំ

ខ. ឈ្មោះ [redacted]ត្រ ហៅ ផែប ភេទប្រុស អាយុ២០ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០៧ឆ្នាំ(ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ពីបទ ប្លន់ (លួចគាស់បន្ទប់យកម៉ូតូ, លុយ, សម្ភារៈ) ប្រព្រឹត្តនៅ ផ្ទះសំណាក់ខូយឡាក់ បន្ទប់លេខ០៩ ម្តុំផ្សារកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- ផ្តន្ទាទោសឈ្មោះ[redacted]ពិសិដ្ឋ ហៅ សាល ហៅ សក់វែង ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៨ឆ្នាំ (ប្រាំបីឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាននិងពិន័យជាប្រាក់ ២.០០០.០០០៛ (ពីរលានរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ប្លន់ (លួចគាស់បន្ទប់យកម៉ូតូ, លុយ, សម្ភារៈ) និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ ផ្ទះសំណាក់ខូយឡាក់ បន្ទប់លេខ០៩ ម្តុំផ្សារកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ និងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។





Scanned with CamScanner

៣- សម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន លើជនជាប់ចោទឈ្មោះ [redacted] ចំរើន, ឈ្មោះ [redacted] វិចិត្រ និងឈ្មោះ [redacted] ពិសិដ្ឋ។

៤- ផ្តន្ទាទោសឈ្មោះ [redacted] សោភ័ណ្ឌ ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ (មួយឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគារ ០៦ខែ (ប្រាំមួយខែ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ទោសសល់ពីនោះ ត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ ៨០០.០០០៛ (ប៉ែតសិបម៉ឺនរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ លក់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩ តាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ។

៥- វត្ថុតាងមានកាំភ្លើងខ្លី ម៉ាកកា៥៤ គ្មានលេខ ចំនួន០១ដើម បង់ចំនួនមួយ គ្រាប់ចំនួន០៣គ្រាប់ អត់ស្នាប់ដៃ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ, រីឯទូរស័ព្ទដៃ ម៉ាកណូគា សេរី២០០ លេខ [redacted] ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ។

៦- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៥៦១ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរ លើឈ្មោះ [redacted] ចំរើន ហៅ ម៉ាច និងឈ្មោះ [redacted] វិចិត្រ ហៅ ឆែប ពីបទ កាន់កាប់រក្សាទុកនូវអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ តាមនីតិវិធី។

៧- សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចំរើន, ឈ្មោ [redacted] វិចិត្រ, ឈ្មោះ [redacted] ពិសិដ្ឋ និងជនរងគ្រោះ។

បើកផ្លូវឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] វិចិត្រ ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤០ ក្រ១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងឈ្មោះ [redacted] សុភ័ក្រ្ត ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] វិចិត្រ ឆ្លើយថា ខ្លួនធ្លាប់ជាប់ពន្ធនាគារម្តង រយៈមួយឆ្នាំកន្លះ ពីបទ បង្ករបួសស្នាមដោយចេតនា, អំពីសកម្មភាព នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ពួកខ្លួន៣នាក់ គឺមានឈ្មោះ [redacted] រើន, ឈ្មោះ [redacted] សិដ្ឋ និងខ្លួន [redacted] វិចិត្រ) ពិតជាបានធ្វើសកម្មភាព គាស់ផ្ទះជនរងគ្រោះ ចូលទៅលួចយកបានរបស់ទ្រព្យមួយចំនួន មានប្រាក់, ទូរស័ព្ទដៃ, ម៉ាស៊ីនថត និងម៉ូតូ០១គ្រឿង ប្រាកដមែន។ ក្នុងការធ្វើសកម្មភាពនេះ គឺឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ចំរើន ជាអ្នកគាស់ ពួកខ្លួនទាំងបីនាក់ចូលទៅក្នុងផ្ទះយករបស់។ សំណូមពរ សុំបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ តាមមាត្រា ៣៨២, ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ជនជាប់ចោទបានឆ្លើយសារភាព និងបញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដើម្បីឲ្យសាលាឧទ្ធរណ៍ជួយសំរាលទោស តំណាងមហាអយ្យការសន្និដ្ឋានតម្កល់សាលក្រមលេខ ៤០ ក្រ១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ តែបើច្បាប់ថ្មីមានលក្ខណៈស្រាលជាង សូមក្រុមប្រឹក្សាពិចារណាលើច្បាប់ថ្មី មាត្រា៣៥៧ និងមាត្រា១០ នៃក្រមព្រហ្មទណ្ឌ សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ឆ្លងកាត់ការសួរដេញដោលក្នុងអង្គសវនាការនាពេលនេះ ក៏ដូចជាបានពិនិត្យមើលកំណត់ហេតុនានាក្នុងសំណុំរឿង ក៏ដូចជាបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ, កូនក្តីខ្លួនឈ្មោះ [redacted] វិចិត្រ ធ្លាប់បានសារភាពថា គាត់ពិតជាបានប្រព្រឹត្តអំពើលួច ដោយមានគ្នា៣នាក់ មានឈ្មោះ [redacted] ហៅ ម៉ាច និងម្នាក់ទៀតឈ្មោះ [redacted] ពិសិដ្ឋ បានប្រព្រឹត្តនៅផ្ទះសំណាក់ខូយឡាក់ បន្ទប់លេខ៩ ម្តុំផ្សារកាបូល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ពិតប្រាកដមែន ហើយចម្លើយរបស់គាត់ឆ្លើយគឺពុំមានភាពស៊ីសង្វាក់គ្នា ជាមួយនឹងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្ត្រ ហើយកូនក្តីខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺដើម្បីសុំនូវស្ថានសម្រាលទោស ដោយសាលាដំបូងភ្នំពេញបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារដល់ទៅ៧ឆ្នាំ ហើយតាមការសន្និដ្ឋានរបស់តំណាងមហាអយ្យការ គឺផ្អែកទៅលើមាត្រា១០ នៃក្រមព្រហ្មទណ្ឌ ហើយតំណាងមហាអយ្យការបានបញ្ជាក់ថា ការផ្តន្ទាសទោសលើកូនក្តីខ្លួន គឺមានលក្ខណៈសមស្របហើយ តាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ, ប៉ុន្តែ កូនក្តីខ្លួន និងបក្សពួកផ្សេងទៀត ត្រូវបានសាលាដំបូងសម្រេចផ្តន្ទាទោស៧ឆ្នាំ គឺមិនមែនតាមមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌទេ គឺតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ សំណូមពរ សុំលោកប្រធាន ក៏ដូចលោកចៅក្រមប្រឹក្សា ពិចារណា ទី១. [illegible]



១៩៧

Scanned with CamScanner

បទចោទ ពីមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកប្រើមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌវិញ តាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ និងសូមផ្តល់នូវស្ថានសម្រាលទោសឲ្យកូនក្តីខ្លួនត្រឹមតែកម្រិតអប្បរមានៃទោស តាមមាត្រា៩៣, ៩៤ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាព្រហ្មទណ្ឌ
## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ចិត្រ ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]ចិត្រ នៅសវនាការនេះថា ខ្លួនធ្លាប់ជាប់ពន្ធនាគារម្តង រយៈមួយឆ្នាំកន្លះ ពីបទ បង្ករបួសស្នាមដោយចេតនា ។ អំពីសកម្មភាព នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ ពួកខ្លួន៣នាក់ គឺមានឈ្មោះ[redacted]ចំរើន, ឈ្មោះ[redacted]ពិសិដ្ឋ និងខ្លួន[redacted]វិចិត្រ) ពិតជាបានធ្វើសកម្មភាពគាស់ផ្ទះជនរងគ្រោះ ចូលទៅលួចយកបានរបស់ទ្រព្យមួយចំនួន មានប្រាក់, ទូរស័ព្ទដៃ, ម៉ាស៊ីនថត និងម៉ូតូមួយគ្រឿង ប្រាកដមែន។ ក្នុងការធ្វើសកម្មភាពនេះ គឺឈ្មោះ[redacted]ពិសិដ្ឋ និងឈ្មោះ[redacted]ចំរើន ជាអ្នកគាស់ ពួកខ្លួនទាំងបីនាក់ចូលទៅក្នុងផ្ទះយករបស់។

៣. តាមលិខិតលេខ ១២៨១០៩ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ថា នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ វេលាម៉ោង១៧:០០នាទី ការិយាល័យនគរបាលបាននាំជនជាប់ចោទ ទៅឃុំនៅបន្ទប់ឃាត់ខ្លួនបណ្តោះអាសន្ន របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់រួចហើយ តែជនជាប់ចោទទាំង៣នាក់ គឺឈ្មោះ[redacted]វិចិត្រ, ឈ្មោះ[redacted]ពិសិដ្ឋ និងឈ្មោះ[redacted]ចំរើន បានអារចម្រឹងដែកបន្ទប់ឃាត់ខ្លួនបណ្តោះអាសន្នរបស់ការិយាល័យ ហើយរត់គេចខ្លួនបាត់តែម្តង។

៤. សាលាដំបូងរាជធានីភ្នំពេញ បានលើកសំអាងហេតុមកបញ្ជាក់គ្រប់សព្វ និងច្បាស់លាស់ហើយ សាលាឧទ្ធរណ៍មិនលើកសំអាងហេតុដដែលនេះឡើងវិញទៀតទេ។

៥. មានភស្តុតាងដាក់បន្ទុកលើជនជប់ចោទឈ្មោះ[redacted]វិចិត្រ ពីបទ ប្លន់ (លួចគាស់បន្ទប់យកម៉ូតូ, លុយ, សម្ភារៈ) ប្រព្រឹត្តនៅ ផ្ទះសំណាក់ខួយឡាក់ បន្ទប់លេខ០៩ ផ្សារកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦. សាលក្រមព្រហ្មទណ្ឌលេខ ៤០ ក្រ១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោ[redacted] វិចិត្រ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤០ ក្រ១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣. បង្គាប់ឲ្យបន្តនូវការឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វិចិត្រ និង មេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

........................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 06 ខែ ... ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner